# ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងប្រទេសកម្ពុជា បច្ចុប្បន្នភាពត្រឹម ខែសីហា ឆ្នាំ២០១៧

## ការត្រួតពិនិត្យជាសកលតាមកាលកំណត់

- ការត្រួតពិនិត្យជាសកលតាមកាលកំណត់ (“យូភីអ”) គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិ (“អ.ស.ប”) ដើម្បីត្រួតពិនិត្យទៅលើការអនុវត្តសិទ្ធិមនុស្សនៃរដ្ឋជាសមាជិក អ.ស.ប នៅរាល់ប្រាំឆ្នាំម្តង។ យន្តការនេះបានចាប់ផ្តើមជាលើកដំបូងនៅ ឆ្នាំ២០០៨។

សម្រាប់ព័ត៌មានបន្ថែមអំពី យូភីអ សូមមើលខិត្តប័ណ្ណព័ត៌មានរបស់ ម.ស.ម.ក ស្តីអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (“យូភីអ”) និងកម្ពុជា ដែលបានចេញផ្សាយក្នុងខែកក្កដា ឆ្នាំ២០១៤ តាមរយៈ *http://cchrcambodia.org/uprleaflet2014kh* និងសលាកប័ត្រព័ត៌មានរបស់អង្គការ UPR Info ស្តីពីការត្រួតពិនិត្យជាសកលតាមកាលកំណត់៖ ព័ត៌មានសម្រាប់អង្គការមិនមែនរដ្ឋាភិបាល តាមរយៈ *https://goo.gl/FfP7pY*

## ប្រទេសកម្ពុជា និង យូភីអ

- ក្នុងអំឡុងពេលនៃការត្រួតពិនិត្យរបស់កម្ពុជាលើកដំបូងនៅឆ្នាំ២០០៩ កម្ពុជាបានទទួលយកអនុសាសន៍ចំនួន៩១ ដែលបានផ្តល់ដោយរដ្ឋផ្សេងៗ ប៉ុន្តែអនុសាសន៍ភាគច្រើននៅពុំទាន់បានអនុវត្តពេញលេញនៅឡើយទេ។
- ក្នុងអំឡុងពេលនៃការត្រួតពិនិត្យលើកទីពីររបស់ខ្លួនក្នុងឆ្នាំ២០១៤ កម្ពុជាបានទទួលយកអនុសាសន៍ចំនួន២០៥។




សម្រាប់ព័ត៌មានបន្ថែម សូមមើលរបាយការណ៍លទ្ធផលនៃការពិគ្រោះយោបល់ថ្នាក់ជាតិក្រោយ យូភីអ របស់ ម.ស.ម.ក នៅឆ្នាំ២០១៤ តាមរយៈ៖ *http://cchrcambodia.org/uproutcomereport2014kh*

- កម្ពុជាបានទទួលយកអនុសាសន៍ជាច្រើនពីបណ្តាប្រទេសនៅសហគមន៍អឺរ៉ុប អាមេរិកខាងត្បូង និងអាហ្វ្រិកខាងជើង ទាក់ទងនឹងវិស័យសំខាន់ៗមួយចំនួនដូចជា ប្រព័ន្ធតុលាការ សិទ្ធិកុមារ សិទ្ធិទទួលបានការអប់រំ និងសិទ្ធិស្ត្រី។
- ម្យ៉ាងទៀត កម្ពុជាត្រូវបានស្នើឱ្យផ្តល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិមួយចំនួនបន្ថែមទៀត។







សម្រាប់ព័ត៌មានបន្ថែម សូមមើលប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អង្គការ UPR Info តាមរយៈ *https://www.upr-info.org/database/*

## ការពិគ្រោះយោបល់ស្តីពី យូភីអ ពាក់កណ្តាលអាណត្តិរបស់កម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០១៧




- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិប្រចាំកម្ពុជា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (“គ.ស.ម.ក”) អង្គការ UPR Info នៅក្នុងទីក្រុងហ្សឺណែវ និងគណៈកម្មការអ្នកច្បាប់អន្តរជាតិ បានសហការរៀបចំសិក្ខាសាលាប្រឹក្សាយោបល់ និងវាយតម្លៃថ្នាក់ជាតិក្នុងបរិបទនៃការត្រួតពិនិត្យលើ យូភីអ ពាក់កណ្តាលអាណត្តិរបស់កម្ពុជា។ សិក្ខាសាលានេះបានប្រព្រឹត្តទៅនៅថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ក្នុងរាជធានីភ្នំពេញ។
- អ្នកចូលរួមភាគច្រើនអញ្ជើញមកពីអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តោតលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការប្រមូលផ្តុំ សិទ្ធិដីធ្លី កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងសិទ្ធិស្ត្រី និងសិទ្ធិកុមារ។
- គោលបំណងនៃការប្រឹក្សាយោបល់នេះគឺដើម្បីពិនិត្យមើលទៅលើការវិវឌ្ឍរបស់កម្ពុជាទាក់ទិនទៅនឹង យូភីអ របស់ប្រទេសនេះចាប់ពីខែមករា ឆ្នាំ២០១៤។
- បើទោះជារាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) បានសម្រេចមិនបញ្ជូនរបាយការណ៍ យូភីអ ពាក់កណ្តាលអាណត្តិក្តី ក៏រដ្ឋាភិបាលបានចូលរួមក្នុងសិក្ខាសាលាប្រឹក្សាយោបល់លើ យូភីអ ពាក់កណ្តាលអាណត្តិនេះផងដែរ តាមរយៈ គ.ស.ម.ក និងក្រសួងយុត្តិធម៌។

សម្រាប់ព័ត៌មានបន្ថែម សូមមើលរបាយការណ៍លទ្ធផលនៃកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ឆ្នាំ២០១៧ តាមរយៈ ៖ *http://cchrcambodia.org/uproutcomereport2017kh*

## វដ្តបន្ទាប់នៃការត្រួតពិនិត្យលើ យូភីអ របស់កម្ពុជា៖ វដ្តលើកទីបីនៃការត្រួតពិនិត្យ

- ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប នឹងធ្វើការត្រួតពិនិត្យ យូភីអ លើប្រទេសកម្ពុជាជាលើកទីបីនៅក្នុងខែមករា ឆ្នាំ២០១៩។

### កាលប្បវត្តិសម្រាប់ចូលរួមក្នុងដំណើរការ យូភីអ នាពេលខាងមុខ




សម្រាប់ព័ត៌មានបន្ថែមអំពីវដ្តលើកទីបីនៃការត្រួតពិនិត្យលើ យូភីអ សូមមើលគេហទំព័ររបស់ការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស តាមរយៈ *https://goo.gl/NPRbPp* និងគេហទំព័ររបស់អង្គការ UPR Info តាមរយៈ *https://www.upr-info.org/en/review/Cambodia*


ផលិតដោយ៖ ម.ស.ម.ក និងអង្គការ UPR Info

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

UPR INFO

ឧបត្ថម្ភដោយ៖

CIVIC SPACE INITIATIVE
ARTICLE 19 · CIVICUS · ICNL



**ទំនាក់ទំនង**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ម.ស.ម.ក តាមរយៈ៖
អាសយដ្ឋានផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
អ៊ីម៉ែល ៖ **info@cchrcambodia.org**
ទូរស័ព្ទ ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១
គេហទំព័រ ៖ **www.cchrcambodia.org**



CC BY NC SA